ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៥០៧ សហវ.ឧហ

# ប្រកាស
## ស្តីពី
## ការដកហូតអាជ្ញាប័ណ្ណឆ្នោតជាបណ្តោះអាសន្នរបស់ ក្រុមហ៊ុនឆ្នោត ហ្វ៊ីរឈូន ឡូធើរី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១.១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០១ នស/រកម ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ហើយមានការកែប្រែក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលត្រូវបានប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១ នស/ ៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងមានការកែប្រែក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលត្រូវបានប្រកាសអោយប្រើដោយព្រះរាជក្រម លេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រមលេខ ០១ ន.ស.រកម ០.១៩៩/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញលិខិតលេខ ៤៥៤ សជណ ចុះថ្ងៃទី ២២ ខែ មិនា ឆ្នាំ ២០០០ របស់ទីស្តីការគណរដ្ឋមន្ត្រី ស្តីពីការសុំធ្វើអាជីវកម្មឆ្នោត ៦ខ្ទង់ ប្រភេទកុំព្យូទ័រ
- បានឃើញសារាចរណែនាំលេខ ០១០ សហវ.សរ ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០០ ស្តីពីកំណែទំរង់ប្រព័ន្ធគ្រប់គ្រងអាជីវកម្ម ឆ្នោត-ឡូតូ
- បានឃើញអាជ្ញាប័ណ្ណឆ្នោត ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០០០ ផ្តល់ជូនក្រុមហ៊ុនឆ្នោត ហ្វ៊ីរឈូន ឡូធើរី
- បានឃើញលិខិតលេខ ១២៨ សហវ.ឧហ ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៣ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីការបន្តសុពលភាពរបស់ក្រុមហ៊ុន
- បានឃើញតំរូវការចាំបាច់របស់ក្រសួង ក្នុងការគ្រប់គ្រងអាជីវកម្មឆ្នោត ឡូតូ អោយមានសណ្តាប់ធ្នាប់

## សំរេច

**ប្រការ ១ :** ដកហូតជាបណ្តោះអាសន្ននូវអាជ្ញាប័ណ្ណឆ្នោតចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០០០របស់ក្រុមហ៊ុនឆ្នោត ហ្វ៊ូឈូន ឡូធើរី ដោយមូលហេតុក្រុមហ៊ុនពុំបានអនុវត្តតាម លិខិតលេខ ១២៨ សហវ.ឧហ ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៣ ។

**ប្រការ ២ :** ការបន្តសុពលភាពអាជ្ញាប័ណ្ណជាថ្មី គឺជាសិទ្ធរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ ៣ :** អគ្គលេខាធិការ នាយកខុទ្ទកាល័យ លោកប្រធាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ លោកប្រធាននាយកដ្ឋានពន្ធដារ លោកប្រធានរតនាគារជាតិ លោកប្រធាននាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ និង អង្គភាពពាក់ព័ន្ធ ព្រមទាំងសាម៉ីក្រុមហ៊ុន ត្រូវទទួលអនុវត្តប្រកាសនេះអោយមានប្រសិទ្ធិភាពខ្ពស់។

**ប្រការ ៤ :** ប្រកាសនេះមានសុពលភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ ២០០៣

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងពាណិជ្ជកម្ម
- សាលាក្រុងភ្នំពេញ

  "ដើម្បីជូនជ្រាប"
- ដូចប្រការ៣

  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ